ការណ៍ពិតអំពីវ៉ាក់សាំង



ការមានគភ៌ និងវ៉ាក់សាំង COVID-19
សំណួរដែលចោទសួរញឹកញាប់

តើអ្នកមានគភ៌ ឬតើជួនកាល អ្នកចង់ឲ្យមានកូន នៅពេលអនាគត ឬទេ? អ្នកប្រហែលជាមានសំណួរ អំពីវ៉ាក់សាំង COVID-19។

តើវ៉ាក់សាំង COVID-19 មានក្តីសុខសំរាប់មនុស្សមានគភ៌ ឬទេ?

មនុស្សជាច្រើន បានក្លាយជាមានគភ៌ និងបានសំរាលកូនដ៏ងែត មានសុខភាពល្អ បន្ទាប់ពីទទួលវ៉ាក់សាំង COVID-19។ វាពុំមានភស្តុតាង ថាវ៉ាក់សាំងបណ្តាលឲ្យរលូតកូន ឬមានបញ្ហាពុំអាចមានគភ៌ក្នុងស្ត្រី ឬបុរស ឡើយ។ វ៉ាក់សាំងនៅតែកំពុងបានសិក្សា ក្នុងមនុស្សមានគភ៌។ ប៉ុន្តែអ្វីៗដែលអ្នកជំនាញៗដឹង គឺអះអាងជាសាថ្មីខ្លាំងណាស់។

តើហេតុអ្វី ខ្ញុំគួរតែចាក់វ៉ាក់សាំង COVID-19 បើសិនខ្ញុំមានគភ៌?

មនុស្សមានគភ៌ ទំនងជាឈឺធ្ងន់ធ្ងរខ្លាំងណាស់ ជាមួយជំងឺ COVID-19 ដោយប្រៀបធៀប ទៅនឹងមនុស្សដែលគ្មានគភ៌។ មនុស្សមានគភ៌ ដែលមាន COVID-19 ក៏បានកើនហានិភ័យនៃការមានគភ៌ដោយមានភាពស្មុគស្មាញ រួមទាំងកូនដ៏ងែតរបស់គេ ឆាប់កើតពេក។ ការចាក់វ៉ាក់សាំង COVID-19 គឺជាមធ្យោបាយល្អបំផុត ដើម្បីការពារខ្លួនអ្នក និងកូនដ៏ងែតរបស់អ្នក។

ចុះបើសិនខ្ញុំ ចង់ឲ្យមានគភ៌ នៅពេលអនាគត?

អ្នកជំនាញៗ ឲ្យអនុសាសន៍យ៉ាងខ្លាំង នូវវ៉ាក់សាំង COVID-19 សំរាប់មនុស្សដែលមានគភ៌ ឬកំពុងបំដៅដោះកូន កំពុងព្យាយាមឲ្យមានគភ៌នៅឥឡូវនេះ ឬក៏អាចនឹងក្លាយជាមានគភ៌ នៅពេលអនាគត។

តើខ្ញុំទៅទីណា បើសិនខ្ញុំមានសំណួរថែមទៀត?

វាជាធម្មតាទេ ដើម្បីមានសំណួរ។ ពិគ្រោះជាមួយ អ្នកផ្តល់ការថែទាំសុខភាព របស់អ្នក ដើម្បីទទួលព័ត៌មានអាចជឿជាក់បាន ដែលអ្នកត្រូវការ ដើម្បីធ្វើការសំរេច ដែលត្រឹមត្រូវសំរាប់អ្នក។



ស្វែងយល់ថែមទៀត នៅ
mass.gov/CovidVaccineFacts